**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ៨០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតមន្ទីរពិសោធន៍ផលិតផលក្លែងក្លាយ ចំណុះក្រសួងមហាផ្ទៃ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១**.-

ត្រូវបានបង្កើត **"មន្ទីរពិសោធន៍ផលិតផលក្លែងក្លាយ"** ចំណុះក្រសួងមហាផ្ទៃ សរសេរកាត់ថា **ម.ព.ផ.ក** ។

**មាត្រា ២**.-

**ម.ព.ផ.ក** មានភារកិច្ចជាអាទិ៍ ដូចខាងក្រោម÷

-ជាសេនាធិការឲ្យក្រសួងមហាផ្ទៃ លើការងារពិសោធន៍គុណភាពផលិតផល ការកំណត់អត្តសញ្ញាណផលិតផល និងលក្ខណៈវិនិច្ឆ័យ នៃផលិតផល

-គ្រប់គ្រង និងថែទាំឧបករណ៍ សម្ភារបច្ចេកទេស របស់**ម.ព.ផ.ក**

-ធ្វើតេស្ត៍ ឬវិភាគផ្នែករូប គីមីសាស្ត្រ មីក្រូជីវសាស្ត្រ មេកានិក អគ្គិសនីអេឡិចត្រូនិក ដើម្បីកំណត់គុណភាព អត្តសញ្ញាណផលិតផល និងលក្ខណៈវិនិច្ឆ័យ នៃផលិតផល តាមការស្នើសុំ និងការចាំបាច់

-ចូលរួម សហការសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ អប់រំ អំពីគុណភាព សុវត្ថិភាពផលិតផល និងផលប៉ះពាល់

-ចូលរួម សហការផ្តល់យោបល់ និងពិគ្រោះយោបល់អំពីផលិតផល

-រៀបចំវិញ្ញាបនបត្រ ឬលិខិតគតិយុត្តិបញ្ជាក់គុណភាពផលិតផលតាមការចាំបាច់ និងតាមគោលការណ៍របស់ក្រសួងមហាផ្ទៃ

-សហប្រតិបត្តិការជាមួយមន្ទីរពិសោធន៍នៃស្ថាប័នជាតិ អន្តរជាតិ និងដៃគូនានា

-បូកសរុបរបាយការណ៍លទ្ធផលការងារ និងទិសដៅការងារអនុវត្តបន្ត ជូនក្រសួងមហាផ្ទៃ
-អនុវត្តភារកិច្ចផ្សេងទៀត ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រគល់ឲ្យ ។

**មាត្រា ៣.-**

**ម.ព.ផ.អ** ដឹកនាំដោយប្រធានមួយរូប មានឋានៈនិងបុព្វសិទ្ធស្មើ ប្រធាននាយកដ្ឋាន ចំណុះក្រសួងមហាផ្ទៃ និងអនុប្រធានមួយចំនួន ជាជំនួយការ មានឋានៈនិងបុព្វសិទ្ធស្មើ អនុប្រធាននាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ ។

**មាត្រា ៤.-**

**ម.ព.ផ.អ** មានការិយាល័យចំណុះមួយចំនួន ។ ការរៀបចំ តួនាទី ភារកិច្ច រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ការិយាល័យនីមួយៗចំណុះ**ម.ព.ផ.អ** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មន្ត្រីនៃ**ម.ព.ផ.អ** ត្រូវតែជាមន្ត្រីដែលមានក្របខ័ណ្ឌនៅក្រសួងមហាផ្ទៃ ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ថ្ងៃចន្ទ ១៥កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ